# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៤៦ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីគោលការណ៍រួមនៃការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ ស្តីពីការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព

- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ស្ថិតនៅក្រោមការដឹកនាំ និងត្រួតពិនិត្យផ្ទាល់របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីដឹកនាំ គ្រប់គ្រង និងត្រួតពិនិត្យរាល់ការបង្កើត និងការដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព ការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ទីភ្នាក់ងារប្រតិបត្តិការពិសេស និងប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងារ និងគណនេយ្យភាពនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។

**មាត្រា ២.-**

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | ប្រធាន |
| ២- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | សមាជិកអចិន្ត្រៃយ៍ |
| ៤ - តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៥ - តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៦ - តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ៧ - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨ - តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩ - តំណាងក្រសួង ស្ថាប័ន សាមី | សមាជិក |

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ត្រូវធានាឱ្យមានការចូលរួមពេញលេញពីគ្រប់ក្រសួង ស្ថាប័ន។

ការតែងតាំងសមាសភាពគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាពត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា ៣.-**

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព មានភារកិច្ចចម្បងៗ ដូចខាងក្រោម :

- ផ្តល់មតិយោបល់លើចំណុចយុទ្ធសាស្ត្រ និងលក្ខណវិនិច្ឆ័យសំរាប់ការរៀបចំ ការបង្កើត ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យលើវាល់ដំណើរការនៃការអនុវត្តន៍កម្មវិធីកន្សោមអាទិភាព ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ទីភ្នាក់ងារប្រតិបត្តិការពិសេស និងប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព
- សម្របសម្រួលលើអភិក្រមនៃការអនុមតិយល់ព្រមលើសំណើរបស់ក្រសួង ស្ថាប័ន
- ត្រួតពិនិត្យលើលទ្ធផលនៃការជ្រើសរើសមន្ត្រីរាជការនៅតាមក្រសួង ស្ថាប័នដែលនឹងត្រូវតែងតាំងឱ្យបំពេញការងារនៅទីភ្នាក់ងារប្រតិបត្តិការពិសេស កម្មវិធីកន្សោមអាទិភាព ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃលើយន្តការ និងដំណើរការនៃការអនុវត្តន៍ទីភ្នាក់ងារប្រតិបត្តិការពិសេស កម្មវិធីកន្សោមអាទិភាព និងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ
- ធ្វើរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍ទីភ្នាក់ងារប្រតិបត្តិការពិសេស កម្មវិធីកន្សោមអាទិភាព និងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ និងផ្សព្វផ្សាយរបាយការណ៍នេះប្រចាំឆ្នាំឱ្យបានទៀងទាត់
- តាមដានត្រួតពិនិត្យការអនុវត្តន៍សេចក្តីសម្រេចនានាពាក់ព័ន្ធទៅនឹងការដាក់ឱ្យដំណើរការយន្តការខាងលើដែលធ្វើឡើងដោយក្រសួង ស្ថាប័ន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលប្រគល់ឱ្យ។

**មាត្រា ៤.-**

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ត្រូវធ្វើអធិការកិច្ចចំពោះក្រសួង ស្ថាប័នដែលបានសុំបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស ឬ ក៏អនុវត្តកម្មវិធីកន្សោមអាទិភាព ឬ អនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ។

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាពត្រូវមានក្រុមការងារអធិការកិច្ចសំរាប់ធ្វើអធិការកិច្ចលើដំណើរការជ្រើសរើសមន្ត្រីឱ្យបំពេញការងារនៅក្នុងទីភ្នាក់ងារប្រតិបត្តិការពិសេស កម្មវិធីកន្សោមអាទិភាព និងការអនុវត្តន៍ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ។

ក្នុងករណីចាំបាច់ គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាពអាចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរជាតិសវនកម្មដើម្បីជួយក្នុងការធ្វើអធិការកិច្ចនេះ។

មាត្រា ៥. -

ការបង្កើត និងការតែងតាំងសមាសភាពក្រុមការងារអធិការកិច្ច ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ។

មាត្រា ៦. -

អនុប្រធាន និងសមាជិកគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រធានគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាពអាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងតំណាងដៃគូអភិវឌ្ឍន៍ឱ្យចូលរួមការប្រជុំតាមការចាំបាច់ ។

មាត្រា ៧. -

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ត្រូវអនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានម៉ឺងម៉ាត់ និងមានស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចឱ្យបានជោគជ័យនូវទិសដៅរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ។

គ្រប់ក្រសួង ស្ថាប័ន ត្រូវសហការ និងជំរុញឱ្យមានប្រសិទ្ធភាពក្នុងការបង្កើត ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យលើការអនុវត្តនីកម្មវិធីកន្សោមអាទិភាព ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ទីភ្នាក់ងារប្រតិបត្តិការពិសេស និងប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ។

មាត្រា ៨. -

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព មានអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ជាលេខាធិការដ្ឋានសំរាប់បំពេញការងារ ។

មាត្រា ៩. -

គ្រប់ក្រសួង ស្ថាប័ន ត្រូវបង្កើតក្រុមការងារគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ដើម្បីសម្របសម្រួលការរៀបចំសំណើ ការបង្កើត ការដាក់ឱ្យដំណើរការ ការគ្រប់គ្រង និងតាមដានត្រួតពិនិត្យការអនុវត្តន៍ទីភ្នាក់ងារប្រតិបត្តិការពិសេស កម្មវិធីកន្សោមអាទិភាព និងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ។

មាត្រា ១០. -

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១១.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ដូចមាត្រា ១១
- ឯកសារ-កាលប្បវត្តិ